**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ៥២០ សទណ.សចក

ថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

## សេចក្ដីជូនដំណឹង

### ស្ដីពីការផ្ដល់រយៈពេលអនុគ្រោះលើកលែងការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (ខារ៉ាអូខេ រង្គសាល-ឌីស្កូតែក បៀរហ្គាឌិន) និងអាជីវកម្មម៉ាស្សាសុខភាព-ស្ប៉ា

**យោង** ÷ - ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍

- ប្រកាសអន្តរក្រសួងលេខ១៦០ សហវ.ប្រក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងទេសចរណ៍។

យោងតាមស្ថានភាពនៃវិបត្តិជំងឺកូវីដ១៩ (COVID-19) ដែលបន្តអូសបន្លាយកាន់តែយូរបង្កផលប៉ះពាល់យ៉ាងច្រើនដល់អាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងម៉ាស្សាសុខភាព-ស្ប៉ា ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូនប្រតិបត្តិករអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងម៉ាស្សាសុខភាព-ស្ប៉ាទូទាំងរាជធានីខេត្តទាំងអស់ មេត្តាជ្រាបថា ក្រសួងទេសចរណ៍ នឹងបន្តផ្ដល់រយៈពេលអនុគ្រោះលើកលែងការពិន័យអន្តរការណ៍ជាប្រាក់ចំពោះអាជ្ញាបណ្ណទេសចរណ៍ដែលផ្ដល់ដោយក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (ខារ៉ាអូខេ រង្គសាល-ឌីស្កូតែក បៀរហ្គាឌិន) និងម៉ាស្សាសុខភាព-ស្ប៉ា ដោយអនុវត្តចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

ទទួលបានសេចក្ដីជូនដំណឹងនេះ សូមប្រតិបត្តករអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (ខារ៉ាអូខេ រង្គសាល-ឌីស្កូតែក បៀរហ្គាឌិន) និងម៉ាស្សាសុខភាព-ស្ប៉ាទូទាំងរាជធានីខេត្តទាំងអស់ ជ្រាបជាដំណឹង។

**ក្រសួងទេសចរណ៍**

**កន្លែងទទួល**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សហព័ន្ធទេសចរណ៍កម្ពុជា
- គ្រប់អាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- គ្រប់អាជីវកម្មម៉ាស្សាសុខភាព-ស្ប៉ា
- ឯកសារ កាលប្បវត្តិ